# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ **ខារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 26-Mar-2020, 11:01
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# ចម្លើយតបរបស់មេធាវីការពារក្ដីលោក ខៀវ សំផន
# ទៅនឹងសំណើសុំបន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញា

---

| ដាក់ដោយ៖ | ដាក់ជូន៖ |
|---|---|
| **មេធាវីការពារក្ដីលោក ខៀវ សំផន** | **អង្គជំនុំជម្រះតុលាការកំពូល៖** |
| មេធាវី គង់ សំអុន | ចៅក្រម គង់ ស្រឹម |
| មេធាវី Anta GUISSÉ | ចៅក្រម Chandra Nihal JAYASINGHE |
| **ជំនួយការ៖** | ចៅក្រម សោម សិរីវឌ្ឍ |
| លោកស្រី សេង សុជាតា | ចៅក្រម Florence Ndepele MWACHANDE-MUMBA |
| កញ្ញា Marie CAPOTORTO | ក្រម ម៉ុង មុន្នីចរិយា |

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

# គោរពជូនអង្គជំនុំជម្រះតុលាការកំពូល

## សេចក្ដីផ្ដើម

១. នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាបានស្នើសុំអង្គជំនុំជម្រះតុលាការ កំពូលឱ្យផ្ដល់ ១៤៥ ទំព័របន្ថែម ដោយបង្កើនចំនួនទំព័រសរុបពី ៣៥០ ទៅ ៤៩៥ ដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ("សំណើ")[1]។

២. តាមរយៈចម្លើយតបនេះ មេធាវីការពារក្ដីរបស់ ខៀវ សំផន ("មេធាវីការពារក្ដី") សូមជំទាស់ទៅនឹងសំណើជ្រុលហួសហេតុនេះ (បន្ថែមជិត ៤២%) ដែលមិនមានហេតុផល និងពន្យឺតកិច្ចដំណើរការនីតិវិធី ដោយឥតប្រយោជន៍។

៣. ជាក់ស្ដែង សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួនត្រូវការ ១៤៥ ទំព័របន្ថែម ដើម្បីឆ្លើយតបទៅនឹងការចោទប្រកាន់នានានៅក្នុងសារណាបណ្ដឹងសាទុក្ខ "បន្ថែម"[2] ដោយឧបសម្ព័ន្ធ ក ចំនួន ៧៦ ទំព័រ និងការយោងទៅរកសារណាពីមុនៗ[3] ដែលសហព្រះរាជាអាជ្ញាប៉ាន់ប្រមាណថា មានយ៉ាងហោចណាស់ ២៣៦ ទំព័រ[4]។ ប៉ុន្តែ ទាំងឧបសម្ព័ន្ធ ទាំងការយោង មិនអាចយកមកប្រើជាហេតុផលសម្រាប់បន្ថែមចំនួនទំព័រ ដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខ បានឡើយ។

៤. ទីមួយ ឧបសម្ព័ន្ធ ក មិនមានការចោទប្រកាន់បន្ថែមណាមួយសោះ។ វាគឺជាតារាងសង្ខេបទឡ្ហីករណ៍ ដែលបានបង្ហាញរួចមកហើយនៅក្នុងសារណា ដែលចង្អុលបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងជាមួយនឹងកំហុសខុសៗគ្នាខ្លាំង ដែលរកឃើញ នៅក្នុងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រកំណត់ សម្រាប់ចម្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ប្រឆាំងនឹងសាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០ ឯកសារ F55 ("សំណើ")។ មេធាវីការពារក្ដីបានទទួលសំណៅបកប្រែជាភាសាបារាំង ពីអង្គភាពបកប្រែភាសា នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០។

[2] សំណើ កថាខណ្ឌ ២ (*"expanded"* នៅក្នុងឯកសារដើម ជាភាសាអង់គ្លេស)។

[3] សំណើ កថាខណ្ឌ ១-២ កថាខណ្ឌ ១០-១១។

[4] សំណើ កថាខណ្ឌ ៩។

ដូច្នេះ ឧបសម្ព័ន្ធនេះមិនមែនជា "ផ្នែកផ្ទាល់" នៃសារណា និងមិនមាន "សារៈសំខាន់"[5] នោះទេ។ សំយោគនេះ គឺជាមធ្យោបាយបន្ថែម ដើម្បីឱ្យអ្នកអានយល់ច្បាស់នៅក្នុងសារណា ៧៥០ ទំព័រ និង មើលឃើញភ្លាមៗនូវទំនាក់ទំនងជាមួយសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ។

៥. ពិតមែនតែគ្មានការចាំបាច់ មេធាវីការពារក្ដីបានធ្វើការងារបន្ថែមខាតពេលនេះ ដើម្បីជួយដល់សហព្រះរាជអាជ្ញា ដែលធ្លាប់បានលើកឡើងអំពីការពិបាកយល់ ក្នុងសំណុំរឿង ០០២/០១ ខណៈដែលប្លង់នៃសារណា ២១០ ទំព័រ ដូចគ្នាស្ទើរតែទាំងស្រុងទៅនឹងសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ[6]។ ដូច្នេះ ឧបសម្ព័ន្ធ ក ជួយសម្រួលដល់ការមើលប្លង់នៃសារណា ក៏ប៉ុន្តែ វាមិនជួយសម្រួលដល់ការយល់នោះទេ។ ជាក់ស្តែង ទឡ្ហីករណ៍ទាំងអស់ ដែលសហព្រះរាជអាជ្ញាត្រូវឆ្លើយតប មាននៅក្នុងសារណាបណ្ដឹងសាទុក្ខ ៧៥០ ទំព័រ។

៦. ទីពីរ ការយោងទៅសារណាមុនៗ ត្រូវបានធ្វើឡើង ដើម្បីជៀសវាងភាពច្រំដែលឥតប្រយោជន៍។ សហព្រះរាជអាជ្ញាធ្លាប់មានឱកាសឆ្លើយតបទៅនឹងសារណាទាំងនេះរួចហើយ និងអាចយោងផងដែរ ដូចតុលាការកំពូលបានកត់សម្គាល់រួចមកហើយ នៅក្នុងសំណុំរឿង ០០២/០១[7]។

៧. ម្យ៉ាងវិញទៀត ការបន្ថែមចំនួនទំព័រដែលស្នើសុំ អាចនឹងបង្កការយឺតយ៉ាវដល់កិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ ដោយសារតែត្រូវបន្ថែមជាសមាមាត្រដោយជៀសមិនរួច នូវកាលកំណត់នៃការបកប្រែ ពីព្រោះថាការបកប្រែនេះ គឺជាចំណុចចាប់ផ្ដើមគិតកាលកំណត់ជាបន្តបន្ទាប់ទៀត[8]។

---

[5] សំណើ កថាខណ្ឌ ៨។

[6] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងសារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **F18/3**។

[7] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំបន្ថែមចំនួនទំព័រ និងពេលវេលា ក្នុងការឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដី ប្រឆាំងនឹងសាលក្រមនៃសំណុំរឿង ០០២/០១ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **F23/1** កថាខណ្ឌ ៩ ("ទាក់ទងនឹងអំណះអំណាងដែលបានលើកឡើងដោយ នួន ជា និង ខៀវ សំផន ដែលបានបញ្ចូលដោយយោងទៅលើឯកសារផ្សេងៗ ដូចជាសារណាពីមុនៗនោះ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការជៀសវាងនូវភាពច្រំដែល ដែលបញ្ហានេះក៏អាចកើតមានចំពោះសហព្រះរាជអាជ្ញាផងដែរ")។

[8] សេចក្ដីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ទៅនឹងបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ **F52/1** កថាខណ្ឌ ២៨ និងកថាខណ្ឌ ៣០។

៨. សរុបសេចក្តីមក ការបន្ថែមចំនួនទំព័រដែលស្នើសុំ គឺមិនមានមូលដ្ឋាន និងពន្យឺតកិច្ចដំណើរការនីតិវិធី ដោយឥតប្រយោជន៍។

៩. <u>**អាស្រ័យហេតុនេះ**</u> មេធាវីការពារក្តី ស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មេត្តា**បដិសេធ**សំណើនេះ។

| | | |
|---|---|---|
| មេធាវី **គង់ សំអុន**<br><br>មេធាវី **Anta GUISSÉ** | ទីក្រុងភ្នំពេញ<br><br>ទីក្រុងប៉ារីស | |